-បានឃើញច្បាប់សារពត៌មានជំពូក ៤ មាត្រាទី ៣២ អនុម័តដោយរដ្ឋសភា នាថ្ងៃទី ៦-៤-៩២

-បានឃើញលិខិតអនុញ្ញាតច្បាប់បើកកាសែត " មនសិការខ្មែរ " លេខ ១៣៤៦-៩៤ ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៩៤ របស់ក្រសួងពត៌មាន ។

-បានឃើញសារពត៌មាន " មនសិការខ្មែរ " ដែលបានចុះអត្ថបទប្រមាថមើលងាយរាជរដ្ឋាភិបាល សភាជាតិ និង អង្គការតុលាការ ។

## សំរេច

**ប្រការ ១ :** សំរេចផ្អាកការផ្សាយរបស់សារពត៌មាន " មនសិការខ្មែរ " ក្នុងរយៈពេល ២ សប្តាហ៍ ចាប់ពីថ្ងៃច័ន្ទ ទី ២៦ ខែ ធ្នូ ១៩៩៤ តទៅក្នុងបទប្រមាថកាត់ទានស្ថាប័នកំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** នៅក្នុងករណីដែលសារពត៌មានមនសិការខ្មែរនៅតែប្រកាន់ជំហរផ្ទុយនឹងក្រមសីលធម៌ផ្ទុយច្បាប់រដ្ឋ ក្រសួងពត៌មាន និង បញ្ឈប់ការផ្សាយហើយបញ្ជូនសំណុំរឿងទៅតុលាការដើម្បីវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៣ :** នាយកដ្ឋានសារពត៌មាននៃក្រសួងពត៌មាន កាសែត " មនសិការខ្មែរ " ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

**ប្រការ ៤ :** ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**

# ៥. ទីស្តីការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៤*

## ប្រកាសលេខ ១៤៨ សករអ

## ស្តីពីថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញច្បាប់ការងារ

-បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០៣ អនក្រ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៣

## សំរេច

**ប្រការ ១** : ថ្ងៃបុណ្យដែលត្រូវឈប់ហើយមានប្រាក់ឈ្នួលនៅឆ្នាំ ១៩៩៥ សំរាប់អ្នកស៊ីឈ្នួលនៃសហគ្រាស គ្រឹះស្ថានទាំងអស់ដែលមានចែងក្នុងមាត្រា ១ នៃច្បាប់ការងារត្រូវបានកំណត់ដូចតទៅ :

-បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃគឺ ថ្ងៃទី ០៨ ខែ មិថុនា ។

-បុណ្យចូលឆ្នាំខ្មែរចំនួនបីថ្ងៃគឺ ថ្ងៃទី ១៤-១៥ និង ១៧ ខែ មេសា ជំនួសថ្ងៃទី ១៦ មេសា ដែលត្រូវចំថ្ងៃអាទិត្យ ។

-បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃគឺ ថ្ងៃទី ០១ ខែ ឧសភា ។

-បុណ្យទិវាកុមារអន្តរជាតិចំនួនមួយថ្ងៃគឺ ថ្ងៃទី ០១ ខែ មិថុនា ។

-បុណ្យទិវាប្រកាសប្រើរដ្ឋធម្មនុញ្ញចំនួនមួយថ្ងៃគឺ ថ្ងៃទី ២៥ ខែ កញ្ញា ជំនួសថ្ងៃទី ២៤ ខែ កញ្ញា ដែលត្រូវចំថ្ងៃ អាទិត្យ ។

-បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃគឺ ថ្ងៃទី ២៣-២៦ និង ២៧ ខែ កញ្ញា ជំនួសថ្ងៃទី ២៤ កញ្ញា ដែលត្រូវចំថ្ងៃអាទិត្យនិងជំនួសថ្ងៃទី ២៥ ខែ កញ្ញា ដែលត្រូវចំថ្ងៃបុណ្យទិវាប្រកាសប្រើរដ្ឋធម្មនុញ្ញ ។

-បុណ្យទិវាសន្និសញ្ញាសន្តិភាពកម្ពុជានៅប៉ារីសចំនួនមួយថ្ងៃគឺ ថ្ងៃទី ២៣ ខែ តុលា ។

-បុណ្យចំរើនព្រះជន្មព្រះមហាក្សត្រចំនួនមួយថ្ងៃកន្លះគឺ ពាក់កណ្តាលថ្ងៃ នៃថ្ងៃទី ៣០-៣១ ខែ តុលា និងទី ០១ វិច្ឆិកា ។

-បុណ្យអុំទូក អកអំបុក សំពះព្រះខែចំនួនមួយថ្ងៃកន្លះគឺ ពាក់កណ្តាលថ្ងៃនៃថ្ងៃទី ០៦-០៧ និង ០៨ ខែ វិច្ឆិកា ។

-បុណ្យឯករាជ្យជាតិចំនួនមួយថ្ងៃគឺ ថ្ងៃទី ០៩ ខែវិច្ឆិកា ។

-បុណ្យសិទ្ធិមនុស្សចំនួនមួយថ្ងៃគឺ ថ្ងៃទី ១១ ខែ ធ្នូ ជំនួសថ្ងៃទី ១០ ធ្នូ ដែលត្រូវចំថ្ងៃអាទិត្យ ។

**ប្រការ ២** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**ស៊ុយ សែម**